Hillside Terrace
Tacoma Housing Authority

Tacoma Housing Authority
902 S L Street
Tacoma, WA 98405

PRSRT FIRST CLASS
U.S. POSTAGE
PAID
SEATTLE, WA
PERMIT NO. 1046

# ដើម្បីព័ត៌មានច្រើនថែមទៀត ឬដើម្បីចូលរួម

▶ ***ចូរទៅមើលព័ត៌មាននៃគំរោងការនៅតូបព័ត៌មានលេខ 2500 Hillside Terrace Offices ។***

▶ ***មានសំណួរឬ? ចូរទាក់ទង:***

Steve Clair
នាយកគ្រប់គ្រងគំរោងការថ្នាក់ឯក
អាជ្ញាធរលំនៅដ្ឋានក្រុងតាខូម៉ា
ទូរស័ព្ទ: (253) 207-4435

អ៊ីមែល: sclair@tacomahousing.org

ការប្រែភាសានៃលិខិតព័ត៌មាននេះ នឹងអាចមាននៅតូបព័ត៌មាននៃគំរោងការ លេខ 2500 Hillside Terrace Office ក្រោយថ្ងៃ 15 ខែកញ្ញា។

9월 15일 이후에 2500 힐사이드 테라스 사무실에 위치한 이번 프로젝트 안내 데스크에 가시면 한글로 번역된 회보를 받아보실 수 있습니다.

ແບບແປພາສາຂອງຂ່າວສານສະບັບນີ້ຈະມີໄວ້ໃຫ້ຢູ່ທີ່ຫນ້າຈໍຄືອອສຢູ່ທີ່ຫ້ອງການ ເດືອນເຊັບເທັມເບີ 15.

После 15 сентября этот информационный листок можно будет получить в переводе на разные языки в информационном киоске проекта по адресу: 2500 Hillside Terrace Office.

Các bản dịch của bản tin này sẽ có ở quầy thông tin về dự án ở Văn Phòng Hillside Terrace số 2500 sau ngày 15 tháng 9.

Hillside Terrace
Tacoma Housing Authority

# ព្រឹត្តប័ត្រនៃការធ្វើឲ្យមានជីវិតថ្មីនៅតំបន់ Hillside Terrace

ការផ្សាយលេខ 1
ខែកញ្ញា ឆ្នាំ 2009

**អាជ្ញាធរលំនៅដ្ឋានក្រុងតាខូម៉ា (THA) បានរុករកជំរើសនានាសំរាប់ការធ្វើឲ្យមានជីវិតថ្មីឡើងវិញនៅប្លុកលេខ 1800 និងប្លុកលេខ 2500 នៃតំបន់ Hillside Terrace ។ អាគារដែលមានអាយុចំណាស់ត្រូវតែសង់ជំនួសឡើងវិញ។ គោលដៅរបស់យើងគឺកែប្រែតំបន់ Hillside Terrace ឲ្យទៅជាសហគមន៍មួយដែលមានគុណភាពខ្ពស់, ផ្ទះប្រកបដោយសុខភាពរស់នៅល្អនិងមានបរិយាកាសដោយមិត្តភាពដែលនឹងជួបតាមសេចក្តីត្រូវការរបស់និវេសកជនហើយនិងធ្វើឲ្យមូលដ្ឋានប្រកបដោយសុវត្ថិភាព, ជាកន្លែងសំរាប់រស់នៅសប្បាយរីករាយយ៉ាងច្រើន។**




## រយៈពេលដំណើរការ

**2009**
- ប្លង់ដើម
- ការប្រជុំសហគមន៍
- ការដាក់ពាក្យសុំសំរាប់សុំជំនួកម្មវិធី HOPE VI

**2010**
- សេចក្តីជូនដំណឹងនៃការទទួលជំនួយកម្មវិធី HOPE VI
- ប្លង់ចុងបញ្ចប់
- ការជ្រើសរើសអ្នកម៉ៅការធ្វើសំណង់

**2011**
- សំណង់ចាប់ផ្តើម

**2012**
- ការចូលទៅរស់
- កន្លែងសំណង់

## តើមានអ្វីកើតឡើងនៅពេលនេះ?

អាជ្ញាធរលំនៅដ្ឋានក្រុងតាខូម៉ាកំពុងដាក់ពាក្យសុំជំនួយពីក្រសួងលំនៅដ្ឋាននៃសហរដ្ឋអាមេរិក និងក្រសួងអភិវឌ្ឍន៍ក្រុង (HUD) ផ្នែកកម្មវិធីជំនួយ HOPE VI ដើម្បីជួយប្រាក់ដល់ការកសាងសំរាប់ការធ្វើ ឲ្យមានជីវិតថ្មីនៃតំបន់ Hillside Terrace ។ យើងនឹងធ្វើការលើផ្នែកនានានៅពេលជាច្រើនខែខាងមុខនេះ ដើម្បីរៀបចំពាក្យសុំជំនួយ ដែលនឹងត្រូវដាក់នៅថ្ងៃទី 17 ខែវិច្ឆិកា ឆ្នាំ 2009 ។

ជំហ៊ានទីមួយដែលសំខាន់បំផុតគឺធ្វើការជាមួយនឹងនិវេសកជន និងអ្នកមានចំណែកនៅក្នុងសហគមន៍ ដើម្បីឲ្យដឹងពីតំលៃ, គំនិត និងសេចក្តីត្រូវការរបស់សហគមន៍។ រយៈពេលពីរឬបីខែខាងមុខនេះ យើងនិងទទួលធ្វើការជួបប្រជុំសហគមន៍ ដើម្បីចែករំលែកនូវព័ត៌មានសំខាន់ៗអំពីគំរោងការ និង ផ្តល់ដល់អង្គប្រជុំដើម្បីដឹងឮពីគំនិតរបស់យើង អំពីអ្វីដែលជារូបរាងនៃតំបន់ Hillside Terrace ហើយនិងដើម្បីឆ្លើយនូវសំណួររបស់អ្នកទាំងអស់គ្នា។ ការចូលរួមរបស់លោកអ្នកគឺជាការសំខាន់ណាស់ — យើងសង្ឃឹមថាអ្នកអាចមកចូលរួមជាមួយយើង!

មធ្យោបាយផ្សេងទៀតគឺដើម្បីសិក្សាអំពីគំរោងការ ដែលមានរួមទាំងការទៅមើលតូបព័ត៌មានគំរោងការនៅ 2500 Hillside Terrace Office ។ យើងក៏នឹងផ្ញើជូននូវព្រឹត្តប័ត្រគំរោងការដូចនេះម្នាក់មួយដល់និវេសកជន នៅផ្នែកសំខាន់ៗនៅក្នុងពេលធ្វើគំរោងការនេះ។ ដោយការកសាងដំណើរការទៅមុខ ក្រុមធ្វើផែនការនឹងបង្កើតវិបសៃផងដែរ។

ចូរបើកទំព័រថ្មីដើម្បីសិក្សាជាច្រើនថែមទៀតអំពីពេលអនាគតនៃតំបន់ Hillside Terrace!

## *ការប្រជុំសហគមន៍នឹងមកដល់*

### សូមទៅចូលរួមជាមួយយើង!

**សិក្ខាកម្មនៃប្លង់សហគមន៍នឹងធ្វើនៅថ្ងៃអង្គារ ថ្ងៃទី 15 ខែកញ្ញា ឆ្នាំ, 2009 វេលាម៉ោង 6:00 ល្ងាចដល់ 8:30 យប់**
ចូរចែករំលែកគំនិតរបស់អ្នកអំពីប្លង់នៃអាគាររបស់បុគ្គលម្នាក់ៗ។

**ការផ្លាស់ប្តូរកន្លែង និងការវិលត្រឡប់ចូលវិញ ប្រជុំនៅថ្ងៃអង្គារ ទី 29 ខែកញ្ញា ឆ្នាំ 2009 វេលាម៉ោង 5:30 ល្ងាច ដល់ 7:00 យប់**
សិក្សាអំពីការផ្លាស់ប្តូរកន្លែងបណ្តោះអាសន្ននៅពេលដំណើការកសាង នឹងការវិលត្រឡប់ នៅពេលដែលគំរោងការត្រូវបានធ្វើរួច។

**ការប្រជុំសហគមន៍ចុងបញ្ចប់ និងថ្ងៃធ្វើសវនាការនឹងត្រូវកំណត់ពេលក្រោយ**
ចូរសិក្សាអំពីលទ្ធផលនៃផែនការដំបូងនិងដំណើរការធ្វើប្លង់។

*គ្រប់ការប្រជុំទាំងអស់នឹងធ្វើនៅ Hillside Terrace Community Room លេខ 2330 South G Street ។ កុមារទាំងអស់យើងទទួលស្វាគមន៍ —កន្លែងក្មេងលេងនឹងមានផ្តល់ជូន។*

# ការចង់ដឹងពីមូលដ្ឋាននៃតំបន់ Hillside Terrace

នៅថ្ងៃទី 18 ខែសីហា ឆ្នាំ 2009, អាជ្ញាធរលំនៅដ្ឋានក្រុងតាខូម៉ា បានទទួលបង្រៀនសិក្ខាកម្មនៃប្លង់សហគមន៍ សំរាប់និវេសកជននៅតំបន់ Hillside Terrace និងអ្នកមានចំណែកទាំងអស់។ ចំនួនលើសពីម្ភៃនាក់នៃសមាជិក សហគមន៍ និងនិវេសកជនបានចែករំលែកគំនិតរបស់ពួកគេអំពីអ្វីដែលអាគារថ្មីគួរមានរូបរាងនិងសួនកំសាន្ត ប្រភេទណាដែលគួរធ្វើ ហើយនិងទំហំសហគមន៍ដើម្បីដាក់បញ្ចូលទៅក្នុងប្លង់។ យើងបានសិក្សាយ៉ាងច្រើន អំពីអ្វីដែលអ្នកចូលរួមក្នុងសិក្ខាកម្មទាំងអស់បានឲ្យតំលៃនិងអ្វីដែលបង្ហាញឲ្យឃើញ ដែលពួកគេចង់ឃើញ ចង់ដាក់បញ្ចូលនៅក្នុងការផ្តល់ជីវិតថ្មីនៅតំបន់ Hillside Terrace ។



## អ្វីដែលយើងបានឮ:

- ចូលចិត្តចង់បានផ្ទះតូច និងរបៀបផ្ទះតាមទីក្រុងពាសពេញអាគារ • អាគារដូចប្រភេទអាគារដែលប្លង់ចង់ធ្វើ។
- ចង់បានអាគារដែលសង់ឲ្យបានពេញចិត្តបំផុតដែលអាច • មានភាពឯកជន, សុវត្ថិភាពនិងពេញដោយភាពស្ងប់ស្ងាត់។
- សួនដំណាំគឺជាការសកម្មភាពសំខាន់ណាស់នៅតំបន់ Hillside Terrace និងទាំងពីរផ្នែក ទាំងភាពឯកជននិងទាំងតំបន់សួនដំណាំសហគមន៍គួរតែបញ្ចូលនៅក្នុងប្លង់។
- ចង់បានមន្ទីរសហគមន៍ ដូចជាកន្លែងលំហាត់ពិសោធន៍កិច្ចការផ្នែកកុំព្យូទ័រឬមជ្ឈមណ្ឌលហាត់ប្រាណ និងសេវាកម្មដូចជា ថ្នាក់បង្រៀនភាសាអង់គ្លេសជាភាសាទីពីរនិងថ្នាក់កុំព្យូទ័រ។
- ផ្ទះបែរមុខទៅរកផ្លូវតូច ឬសួនកំសាន្ត ឬទីធ្លាដែលមានអាគារព័ទ្ធជុំវិញ, នៅឆ្ងាយពីផ្លូវអ៊ូរអរ, ដើម្បីឲ្យមានភាពឯកជន, សុវត្ថិភាពយ៉ាងច្រើន, និងបន្ថយភាពអឹងកង។
- បន្ថែមហោណាំង, ច្រកចូលមានដើមឈើសងខាង, និងធ្វើដីដាំដំណាំដើម្បី "មើលទៅឃើញដូចជាមានសួនអ្វីៗគ្រប់"។
- ផ្តល់ទីធ្លារស់នៅរបៀបទូទៅ ដែល "ទាញអារម្មណ៏និវេសកជនឲ្យចេញទៅកំសាន្តនៅក្រៅផ្ទះ" ដូចជាកន្លែងអាំងសាច់ខាងក្រៅ, កន្លែងអង្គុយលេង, និងកន្លែងលេងកំសាន្តសំរាប់ក្មេងជាដើម។
- ធ្វើកន្លែងចតរថយន្តនៅជិតអាគាររស់នៅ ដើម្បីអាចមើលឃើញរថយន្តពីខាងក្នុងអាគាររស់នៅ។









### ចូរប្រាប់យើងនូវអ្វីដែលអ្នកគិត!

តើអាគារ, កន្លែងចតរថយន្ត, និងមន្ទីរសហគមន៍ប្រភេទណាដែលអ្នកចង់ឃើញនៅតំបន់ Hillside Terrace ថ្មី? តើអ្វីដែលអ្នកចូលចិត្តឬមិនចូលចិត្តអំពីតំបន់ Hillside Terrace today ពេលបច្ចុប្បន្ន? **សូមបំពេញ ក្រដាសពាក្យនៃការឲ្យយោបល់ដែលភ្ជាប់មកជាមួយ ដើម្បីផ្ញើយោបល់និងសំណើរបស់អ្នក។**

សេចក្តីថ្លែងរបស់ក្រុមប្រឹក្សាមកពីសិក្ខាកម្មថ្ងៃទី 18 ខែសីហា ពេលបច្ចុប្បន្ននេះគឺបានបិទបង្ហាញ នៅតួបគំរោងការព័ត៏មាន នៅលេខ 2500 Hillside Terrace Office ហើយនឹងត្រូវយកទៅបិទបង្ហាញ នៅទីកន្លែងជាច្រើនទៀតទូទាំងបរិវេណប្លុកលេខ 1800 និង 2500 Hillside Terrace ។ សូមអញ្ជើញឈៀងចូល!

# សូមអញ្ជើញចូលរួមជាមួយយើងនៅពេលធ្វើសិក្ខាកម្មសហគមន៍ លើកក្រោយ!

សិក្ខាកម្មនៃប្លង់សហគមន៍លើកក្រោយ គឺធ្វើនៅថ្ងៃអង្គារ ថ្ងៃទី 15 ខែកញ្ញា ឆ្នាំ 2009 ។ ក្រុមស្ថាបត្យករនឹងស្នើសុំ ពីយោបល់របស់លោកអ្នក អំពីប្លង់នៃអាគារលំនៅដ្ឋានសំរាប់បុគ្គលម្នាក់ៗនៅតំបន់ Hillside Terrace ថ្មី និងជំរើសចុងបញ្ចប់ ដូចជា ពណ៌ថ្នាំ, ក្រាលកម្រាល, និងលក្ខណៈពិសេសៗផ្សេងទៀត។

**ថ្ងៃអង្គារ ទី 15 ខែកញ្ញា ឆ្នាំ 2009 ម៉ោង 6:00–8:30 យប់ — មានអាហារពេលល្ងាច!**
**នៅ Hillside Terrace Community Room**
**ប្លុកលេខ 2300 នៃ G Street**

អាហារពេលល្ងាចយ៉ាងហ៊ោរហៀរ, អាហារពិសេសៗមកពីហាងលក់ដូរក្នុងមូលដ្ឋាននឹងត្រូវផ្តល់ជូនពិសារ។ ចូរយកជាប់ជាមួយនូវយោបល់របស់អ្នកនិងចំណង់បរិភោគរបស់អ្នក!

កន្លែង Hillside Terrace community room គឺអាចចេញចូលបានសំរាប់មនុស្សដែលមានភាពពិការ។ អ្នកបកប្រែភាសា វៀតណាម, ខ្មែរ, កូរ៉េ, លាវ, និងរុស្ស៊ី នឹងអាចមានបំរើជូននៅពេលប្រជុំ។ កុមារទាំងអស់យើងទទួលស្វាគមន៍ — កន្លែងក្មេងលេងនឹងមានផ្តល់ជូន។

# តើតំបន់ Hillside Terrace ថ្មីអាចមើលទៅដូចអ្វី?



ចំណែកចន្លោះនៃសួនច្បារដែលមានធុងទំហំខុសៗគ្នា



កន្លែងសួនដំណាំសហគមន៍





ប្រភេទលំនៅដ្ឋានដែលអាចសង់បាន